# តើខ្ញុំគួរធ្វើចត្តាឡីស័ករយៈពេលប៉ុន្មានថ្ងៃ?



## តើអ្វីទៅជាការធ្វើចត្តាឡីស័ក?



ការធ្វើចត្តាឡីស័កជាការដាក់ឱ្យបុគ្គលដែលអាចប៉ះពាល់វីរុស SARS-CoV-2 ដែលបង្កឱ្យមានជំងឺ COVID-19 នៅឆ្ងាយពីអ្នកដទៃ។

## តើខ្ញុំគួរធ្វើចត្តាឡីស័ករយៈពេលប៉ុន្មានថ្ងៃ?

| មិនបានចាក់វ៉ាក់សាំង | បានចាក់វ៉ាក់សាំងពេញលេញ |
|---|---|
| សូមណែនាំឱ្យអ្នកដែលមានការប៉ះពាល់ជិតស្និទ្ធទៅធ្វើតេស្តរកមេរោគ COVID-19.។ សម្រាប់អ្នកដែល**មិនបានចាក់វ៉ាក់សាំង** មានជម្រើសចំនួនពីរដើម្បីកំណត់រយៈពេលធ្វើចត្តាឡីស័ករបស់អ្នក។ សូមបញ្ជាក់ថា ថ្ងៃប៉ះពាល់គឺត្រូវចាត់ទុកជាថ្ងៃ 0។<br><br>*ជម្រើសទី1៖* អ្នកគួរស្នាក់នៅផ្ទះរយៈពេល 10 ថ្ងៃបន្ទាប់ពីមានការប៉ះពាល់ប្រសិនបើអ្នកពុំធ្វើតេស្ត COVID។<br><br>*ជម្រើសទី2៖* អ្នកគួរស្នាក់នៅផ្ទះរយៈពេល 7 ថ្ងៃ ហើយអាចចាក់ចេញនៅថ្ងៃទី 8 ប្រសិនបើអ្នកធ្វើតេស្តអវិជ្ជមាន COVID (ការធ្វើតេស្តត្រូវធ្វើឡើង**នៅថ្ងៃទី 5 ឬបន្ទាប់ពីនេះ**)។ ប្រសិនបើអ្នកមានលទ្ធផលវិជ្ជមាន ឬអ្នកមានរោគសញ្ញា COVID អ្នកត្រូវដាក់ខ្លួននៅដាច់ដោយឡែក<u>ភ្លាមៗ</u> និងសូមទាក់ទងទៅអ្នកផ្តល់សេវាសុខភាពរបស់អ្នក ឬនាយកដ្ឋានសុខភាពសាធារណៈដើម្បីទទួលការណែនាំអំពីការដាក់ខ្លួននៅដាច់ដោយឡែក។ | បុគ្គលដែលចាក់វ៉ាក់សាំងរួចដែលបានប៉ះពាល់ជាមួយបុគ្គលដែលសង្ស័យ ឬត្រូវបានបញ្ជាក់ថាមានជំងឺ COVID-19 ពុំចាំបាច់ធ្វើចត្តាឡីស័កឡើយប្រសិនបើបំពេញនូវលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖<br><br>• មានរយៈពេលយ៉ាងតិច 2 សប្តាហ៍គិតចាប់ពីពេលបានចាក់វ៉ាក់សាំងដូសចុងក្រោយ។ ដូសវ៉ាក់សាំងចុងក្រោយមានន័យថាជាដូសទី 2 សម្រាប់ប្រភេទវ៉ាក់សាំង 2 ដូស (ដូចជា Pfizer, Moderna ឬវ៉ាក់សាំងដែលអង្គការសុខភាពពិភពលោកទទួលស្គាល់ ដូចជា Covishield ឬ AstraZeneca) ឬ 1 ដូសនៃវ៉ាក់សាំងប្រភេទមួយដូស (Johnson & Johnson)<br><br>**និង**<br><br>• ពុំមានរោគសញ្ញា COVID-19 គិតចាប់ពីពេលប៉ះពាល់ផ្ទាល់លើកចុងក្រោយ<br><br>ទោះបីគ្មានរោគសញ្ញា បុគ្គលដែលចាក់វ៉ាក់សាំងរួចគួរធ្វើតេស្តនៅរយៈពេល 5-7 ថ្ងៃបន្ទាប់ពីប៉ះពាល់ជាមួយករណីជំងឺ COVID-19។ |

**នាយកដ្ឋានសុខភាពសាធារណៈ California បានចេញគោលការណ៍ណែនាំថ្មីចុងក្រោយអំពីការធ្វើចត្តាឡីស័ក COVID-19 ស្របទៅតាមគោលការណ៍ណែនាំរបស់ CDC ដែលរកបានតាមរយៈ** https://bit.ly/3hWbBPo

**បទបញ្ជារបស់មន្ត្រីសុខាភិបាលខោនធី Alameda ស្តីពីការធ្វើចត្តាឡីស័កដែលមាននៅលើ** https://bit.ly/3kznDQk។ **សម្រាប់ការណែនាំពេញលេញអំពីការធ្វើចត្តាឡីស័ក សូមមើលខ្លឹមសារលម្អិតស្តីពីការដាក់ខ្លួននៅដាច់ដោយឡែក/ការធ្វើចត្តាឡីស័កនេះ** https://bit.ly/3hYz7vc។ **ប្រសិនបើអ្នកមិនអាចចូលតំណភ្ជាប់នេះ សូមទាក់ទងទៅលេខ 510.268.2101 ហើយខ្លឹមសារអាចផ្ញើទៅអ្នកតាមអ៊ីមែល។**

**ALAMEDA COUNTY HEALTH CARE SERVICES AGENCY**
**PUBLIC HEALTH DEPARTMENT**

**Colleen Chawla** – Agency Director
**Kimi Watkins-Tartt** – Director
**Nicholas Moss, MD** – Health Officer

Contact

Public Health Department:
(510) 267-8000 Main Line

COVID-19 Information:
(510) 268-2101

www.acphd.org